ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 11-Apr-2016, 12:13
CMS/CFO: Sann Rada

# អនុស្សរណៈអន្តរការិយាល័យ
# INTEROFFICE MEMORANDUM

**ផ្ញើពី/From:** **ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល („ក្រឡាបញ្ជី")**
**Greffiers of the Supreme CourtChamber (the "Greffiers")**

ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦
Date: 11 April 2016

**ផ្ញើជូន/To:** **ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង**
**Greffiers of the Trial Chamber**

**ចម្លងជូន/ CC:** **ចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល**
**ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង**
**ភាគីនៃសំណុំរឿង ០០២**
**Judges of the Supreme Court Chamber;**
**Judges of the Trial Chamber;**
**Parties to Case 002**

**កម្មវត្ថុ/ Subject:** **ការឆ្លើយតបទៅនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ (E375/2)**
**Response to Trial Chamber's Memorandum of 9 March 2016 (E375/2)**

យោងតាមអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ (E375/2) បានស្នើសុំចូលមើល"ឧបសម្ព័ន្ធ–កំណត់ហេតុរបស់ Robert LEMKIN ស្តីពីគោលនយោបាយរបស់ រស់ ញឹម" **(F2/4/3/3.1)**, "ប្រតិចារឹកនៃកំណត់ហេតុស្តាប់ចម្លើយដែលបានផ្តល់ដោយ LEMKIN" **(F2/4/3/3/6.2)**, "ឧបសម្ព័ន្ធ ២: កិច្ចសម្ភាសន៍របស់ ទាត់ ធឿន ជាមួយនឹង ថេត សម្បត្តិ និង Robert LEMKIN" **(F2/9.2)**, "ចម្លើយតបទៅនឹងសំណួរស្តីពីកិច្ចស៊ើបសួរបន្ថែមរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងជើងនៅក្នុងឈុតវីដេអូ ដែលជាកម្មសិទ្ធិរបស់ផលិតករភាពយន្ត Rob LEMKIN និង THET Sambath" **(F2/4/3/3/1)**, "សេចក្តីសង្កេតរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងការបង្គាប់ឱ្យស្វែងរកព័ត៌មានបន្ថែម" **(F2/4/3/3/2)**, "ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងចម្លើយតបរបស់ នួន ជា ទៅនឹង

សំណួរនានាស្តីពីកិច្ចស៊ើបសួរបន្ថែមរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងឈុតវីដេអូដែលជាកម្មសិទ្ធិរបស់ផលិតករភាពយន្ត ថេត សម្បត្តិ និង Rob LEMKIN” (**F2/4/3/3/3**), “សារណាឆ្លើយតបរបស់ នួន ជា ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា ជូនអង្គជំនុំជម្រះតុលាការកំពូល ឱ្យស៊ើបអង្កេតបន្ថែមទៅនឹងខ្សែវីដេអូរបស់ផលិតករ Rob LEMKIN និង ថេត សម្បត្តិ” (**F2/4/3/3/4**), និង “កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី–Robert T.F. LEMKIN” (**F2/4/3/1**) (ជារួម “ឯកសារដែលត្រូវបានស្នើសុំ”)។ នៅក្នុងអនុស្សរណៈនេះ អង្គជំនុំជម្រះសាលាដំបូងបារំឭកថា អង្គជំនុំជម្រះបានទទួលសំណើសុំស្តាប់ Robert LEMKIN ក្នុងឋានៈជាសាក្សីក្នុងសំណុំរឿង ០០២/០២ និងបានអះអាងថា ដើម្បីសម្រេចលើសំណើនេះ អង្គជំនុំជម្រះនឹងត្រូវពិចារណាលើឯកសារសម្ងាត់មួយចំនួន ដែលមាននៅក្នុងក្របខ័ណ្ឌនៃកិច្ចស៊ើបសួររបស់បន្ថែមរបស់អង្គជំនុំជម្រះតុលាការកំពូល។

ជាការចាប់ផ្តើម ក្រឡាបញ្ជីបានកត់សម្គាល់ឃើញថា ឯកសារពីរដែលបានស្នើសុំនោះ ត្រូវបានដាក់ចំណាត់ថ្នាក់ជាសាធារណៈរួចហើយ (**F2/9.2** និង **F2/4/3/3/2**), និងថា ជាការពុំចាំបាច់សម្រេចលើសំណើសុំមើលឯកសារនេះឡើយ។

ឯកសារលេខ **F2/4/3/3.1**, **F2/4/3/3/6.2**, **F2/4/3/3/1**, **F2/4/3/3/3** និង **F2/4/3/3/4** ត្រូវបានដាក់ចំណាត់ថ្នាក់ជាសម្ងាត់ដោយសារមានការយល់ព្រមជាមួយ Robert LEMKIN ថា អង្គជំនុំជម្រះនឹងដាក់ចំណាត់ថ្នាក់ជាសម្ងាត់លើឯកសាររបស់គាត់ និងមិនបង្ហាញដោយគ្មានការអនុញ្ញាតជាមុនពីរូបគាត់ឡើយ។ ក្រឡាបញ្ជី តាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញ (“WESU”) ដែលបានសួរនាំ Robert LEMKIN ទាក់ទងទៅនឹងថាតើ គាត់ មានការជំទាស់លើបញ្ហានៃការបង្ហាញឯកសារខាងលើទៅអង្គជំនុំជម្រះ ដែរ ឬយ៉ាងណា។ នៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៦ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ បានជូនដំណឹងក្រឡាបញ្ជីថា Robert LEMKIN ពុំមានការជំទាស់ឡើយ ប៉ុន្តែស្នើសុំថា ឯកសារ ត្រូវតែបង្ហាញក្រោមលក្ខខណ្ឌជាការសម្ងាត់ដដែល។ អាស្រ័យហេតុនេះក្រឡាបញ្ជី ដោយពិចារណាឃើញថា ដើម្បីផលប្រយោជន៍យុត្តិធម៌ បានអនុញ្ញាតការបង្ហាញឯកសារខាងលើដល់អង្គជំនុំជម្រះសាលាដំបូងក្រោមលក្ខខណ្ឌថា ការបង្ហាញណាបន្តទៀតពុំអាចធ្វើទៅបានឡើយ ប្រសិនបើពុំមានការអនុញ្ញាតជាមុនពីអង្គជំនុំជម្រះតុលាការកំពូល។

សម្រាប់ឯកសារលេខ **F2/4/3/1** ពុំមានការសន្យាអំពីការរក្សាការសម្ងាត់ឡើយ។ ក្រឡាបញ្ជីពិចារណាឃើញថា គឺដើម្បីប្រយោជន៍យុត្តិធម៌ដែលត្រូវបង្ហាញឱ្យទាំងនេះដល់អង្គជំនុំជម្រះសាលាដំបូង។

បង្គាប់មន្ត្រីកាន់សំណុំរឿង ត្រូវអនុវត្តអនុស្សរណៈនេះ ដោយអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងចូលមើលឯកសារលេខ **F2/4/3/3.1**, **F2/4/3/3/6.2**, **F2/4/3/3/1**, **F2/4/3/3/3, F2/4/3/3/4** និង**F2/4/3/1**។

Reference is made to the Trial Chamber's Memorandum of 9 March 2016 (E375/2), requesting access to "Annex – Robert LEMKIN's Notes on RUOS Nhim's Political Agenda" (**F2/4/3/3.1**), "Transcripts of Interviews Provided by Robert LEMKIN" (**F2/4/3/3/6.2**), "Annex 2: Interviews of TOAT Thoeun with THET Sambath and Robert LEMKIN" (**F2/9.2**), "NUON Chea's Response to Questions on the Supreme Court Chamber's Additional Investigation into Footage in the Possession of Filmmakers Rob LEMKIN and THET Sambath" (**F2/4/3/3/1**), "Submissions from Mr KHIEU Samphân's Defence concerning the Additional Investigation Ordered" (**F2/4/3/3/2**), "Co-Prosecutors' Response to NUON Chea's Response to Questions on the Supreme Court Chamber's Investigation into Footage in the Possession of Filmmakers Rob LEMKIN and THET Sambath" (**F2/4/3/3/3**), "NUON Chea's Reply to Co-Prosecutors' Response to NUON Chea's Questions on the Supreme Court Chamber's Additional Investigation into Footage in the Possession of Filmmakers Rob LEMKIN and THET Sambath" (**F2/4/3/3/4**), and "Written Record of Witness Interview – Robert T.F. LEMKIN" (**F2/4/3/1**) (collectively, the "Requested Documents"). In its Memorandum, the Trial Chamber recalled that it is seised of a request to hear Robert LEMKIN as a witness in Case 002/02 and affirmed that, in order to dispose of such request, it would take into consideration some confidential documents obtained in the framework of the Supreme Court Chamber's additional investigation.

At the outset, the Greffiers note that two of the Requested Documents are already classified as public (**F2/9.2** and **F2/4/3/3/2**), and that therefore it is unnecessary to rule on the related request for access.

Documents Nos **F2/4/3/3.1**, **F2/4/3/3/6.2**, **F2/4/3/3/1**, **F2/4/3/3/3** and **F2/4/3/3/4** are classified as confidential in order to observe an agreement with Robert LEMKIN that the Supreme Court Chamber would treat confidentially the documents submitted by him and not disclose them any further without his prior authorisation. The Greffiers, through the Witnesses and Experts Support Unit ("WESU"), enquired with Robert LEMKIN as to whether he has any objections to the disclosure of said documents to the Trial Chamber. On 31 March 2016, the WESU informed the Greffiers that Robert LEMKIN did not raise any objection, but requested that the documents be disclosed under the same terms of confidentiality. Accordingly, the Greffiers, considering that the interests of justice so dictate, permit the disclosure of the aforementioned documents to the Trial Chamber under the condition that no further disclosure be effectuated without prior authorisation from the Supreme Court Chamber.

As for document No. **F2/4/3/1**, no agreement of confidentiality exists. The Greffiers consider that it is in the interests of justice to disclose such document to the Trial Chamber.

The Case File Officer is directed to implement the present Memorandum, granting the Trial Chamber access to documents Nos **F2/4/3/3.1**, **F2/4/3/3/6.2**, **F2/4/3/3/1**, **F2/4/3/3/3, F2/4/3/3/4** and **F2/4/3/1**.